**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៦៦៤ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការទប់ស្កាត់ប្រភេទត្រីចាបទឹកសាប

*********

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តាមសំណើរបស់នាយកដ្ឋានជលផល

## សម្រេច

**ប្រការ ១:** ហាមឃាត់ការនាំចូល ការចិញ្ចឹម និងការលក់ដូរប្រភេទត្រីចម្លែកដែលបងប្អូនប្រជាពលរដ្ឋនិយមហៅថាត្រីចាបទឹកសាប ស្ថិតនៅក្នុងអំបូរ ពីរ៉ាន់ណា នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២:** នាយកដ្ឋានជលផលត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ជាបន្ទាន់ដល់វារីវប្បករ និង អាជីវករលក់ដូរផលនេសាទឱ្យបញ្ឈប់ការចិញ្ចឹម និងការលក់ដូរប្រភេទត្រីដូចមានចែងក្នុងប្រការ ១ ខាងលើ ហើយត្រូវពន្យល់ បង្ហាញនូវផលប៉ះពាល់ជាអវិជ្ជមាននៃការចិញ្ចឹមត្រីប្រភេទនេះ នៅពេលដែលវារួចចូលទៅក្នុងដែនទឹកធម្មជាតិ ។

**ប្រការ ៣:** ជនណាប្រព្រឹត្តល្មើសនឹងប្រការ១ នៃប្រកាសនេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៣៨ មាត្រា ៣៩ និងមាត្រា ៤០ នៃក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ។

**ប្រការ ៤:** ជនណាឆ្លៀតយកឥទ្ធិពល និង អំណាចនៅក្នុងមុខងាររបស់ខ្លួន ដើម្បីប្រព្រឹត្តបទល្មើស ឬ ឃុបឃិត បិទបាំង ការពារអំពើល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥:** ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦:** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង និងប្រធានការិយាល័យជលផលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងបរិស្ថាន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ